

# បងស្រី បងស្រី ហេតុអ្វីបានជាវត្ថុ មិនធ្លាក់ឡើងលើ?

Let's Read
The Asia Foundation



បងស្រី បងស្រី ខ្ញុំឆ្ងល់... ឆ្ងល់អ្វីទៅ ឆ្ងល់អ្វីទៅ ប្អូនប្រុស? ខ្ញុំឆ្ងល់ ខ្ញុំឆ្ងល់ថា ហេតុអ្វីវត្ថុមិនជ្រុះឡើងលើ។ តើប្អូនគិតយ៉ាងណាដែរ គិតយ៉ាងណាដែរ ប្អូនប្រុស? ខ្ញុំគិត ខ្ញុំគិតថា... ប្រាប់បងមក៏ តើប្អូនគិតយ៉ាងណាដែរ ប្អូនប្រុស?



ខ្ញុំគិតថា ជាយូរលង់ណាស់មកហើយ វត្ថុគឺធ្លាក់ឡើងលើមេឃមែន ហើយផ្ទៃមេឃពោរពេញទៅដោយសម្បកស្ករគ្រាប់ និងដងឈើការ៉េមជ្រុះរាយប៉ាយ ហើយផ្កាយរអិលដួលដោយសារតែជាន់លើសម្បកចេក ពេលខ្លះព្រះចន្ទមុតជើងដោយសារតែជាន់លើអំបែងកែវ ហើយសំពត់ភ្លឺផ្លេកពណ៌ទឹកប្រាក់របស់ព្រះចន្ទរហែកដោយសារតែទាក់ជាមួយដែកគោលច្រែះ។



ខ្ញុំគិតថា ស្ត្រីចំណាស់នៅលើមេឃ ពិតជាហត់នឿយនឹងការសម្អាតសំរាមទាំងនោះពេកក៏ដាក់បណ្ដាសាមកផែនដី ឱ្យវត្ថុធ្លាក់ចុះក្រោមវិញតាំងពីពេលនោះមក។

ខ្ញុំគិតថាវាជាមូលហេតុដែលវត្ថុមិនធ្លាក់ឡើងលើ ពីព្រោះស្ត្រីចំណាស់នៅលើមេឃនោះធុញថប់នឹងការរស់នៅជាមួយក្លិនស្អុយដូចទ្រុងជ្រូក។ ខ្ញុំឆ្លាតណាស់ មែនទេបងស្រី?



ចាំ ប្អូនពិតជាឆ្លាតមែន។ ប្រហែលត្រូវដែរ ... ប៉ុន្តែក្នុងសៀវភៅដែលបងបានអាន គេមិនថាដូច្នេះទេ។ ចុះគេថាយ៉ាងដូចម្ដេចវិញ គេថាយ៉ាងដូចម្ដេចវិញ បងស្រី? តើប្អូនគិតយ៉ាងណាដែរ គិតយ៉ាងណាដែរ ប្អូនប្រុស? ខ្ញុំគិត ខ្ញុំគិតថា ... ប្រាប់បងមក៏ តើប្អូនគិតយ៉ាងណាដែរ ប្អូនប្រុស?



ខ្ញុំគិតថា ជាយូរលង់ណាស់មកហើយ វត្ថុគឺធ្លាក់ឡើងលើមេឃ
មែន ហើយធ្វើអោយម៉ាក់ខឹងក្តៅក្រហាយ។ កូនសោរបស់ប៉ា
ទងក្រវិលរបស់ម៉ាក់ កាក់ដែលបងបោះលេងចុះឡើងពេលមក
ពីផ្សារ (បងដឹងហើយ ម៉ាក់ដឹង ម៉ាក់នឹងស្តីឱ្យ) កាក់ទាំងអស់
ធ្លាក់ឡើងទៅលើបាត់អស់។



ម៉ាក់បានបន់អស់ទេវតា។ ទេវតាមួយអង្គបានអាណិត
ម៉ាក់ ហើយវត្ថុទាំងអស់ក៏ធ្លាក់ចុះក្រោម លែងបាត់ទៅណា
ទៀតហើយ។ ម៉ាក់សប្បាយចិត្ត (បានមួយភ្លែត) ឥឡូវគាត់
ក៏ចាប់ផ្ដើមឡូឡាពីរឿងសំរាមដែលនៅរាយប៉ាយពេញដី។
ខ្ញុំគិតថាវាជាមូលហេតុដែលវត្ថុមិនធ្លាក់ឡើងលើ ទាំងអស់
នេះគួរតែអរគុណចំពោះការបួងសួងរបស់ស្ត្រីម្នាក់ ដែលធ្វើឱ្យ
មិនសូវបាត់កាក់ ទងក្រវិល និងកូនសោ។ ខ្ញុំឆ្លាតណាស់ មែនទេ
បងស្រី?



ចាំ ប្អូនពិតជាឆ្លាតមែន។ ប្រហែលត្រូវដែរ ... ប៉ុន្តែក្នុងសៀវភៅដែលបងបានអាន គេមិនថាដូច្នេះទេ។ ចុះគេថាយ៉ាងដូចម្ដេចវិញ គេថាយ៉ាងដូចម្ដេចវិញ បងស្រី? តើប្អូនគិតយ៉ាងណាដែរ គិតយ៉ាងណាដែរ ប្អូនប្រុស? ខ្ញុំគិត ខ្ញុំគិតថា ... ប្រាប់បងមក៏ តើប្អូនគិតយ៉ាងណាដែរ ប្អូនប្រុស?



ខ្ញុំគិតថាមានបិសាចដ៏លោភលន់ម្នាក់បង្កប់ក្នុងភពផែនដី គេចាំពេញមួយថ្ងៃ ចាំបើកមាត់ចំហបឺតស្រូបខ្យល់ ... ហើយគ្មានវត្ថុអ្វីអាចជ្រុះឡើងលើទេ ឱ្យតែគេបន្តស្រូបយក - អ្វីៗគ្រប់យ៉ាងធ្លោះទៅកាន់រន្ធមាត់ល្មោភនោះ។



ខ្ញុំគិតថាវត្ថុជាច្រើនបានធ្លាក់ទៅក្នុងនោះ។ ឃ្លីរបស់ខ្ញុំ តង្កៀបសក់របស់បង និងនំស្រួយដែលម៉ាក់បានធ្វើឱ្យយើង ។ ខ្ញុំគិតថាវាជាមូលហេតុដែលវត្ថុមិនធ្លាក់ឡើងលើ ពីព្រោះវាធ្លាក់ឆ្ពោះមកផែនដី ដើម្បីទៅចិញ្ចឹមយក្សល្មោភនៅក្រោមដី។ ខ្ញុំឆ្លាតណាស់មែនទេបងស្រី?



ចាំ ប្អូនពិតជាឆ្លាតមែន។ ប្រហែលត្រូវដែរ ... ប៉ុន្តែក្នុងសៀវភៅដែលបងបានអាន គេមិនថាដូច្នេះទេ។ ចុះគេថាយ៉ាងដូចម្ដេចវិញ គេថាយ៉ាងដូចម្ដេចវិញ បងស្រី?



មកនេះប្អូនប្រុស បងនឹងប្រាប់ប្អូនគេថាអ្វីខ្លះ។ គេនិយាយ គេនិយាយថា ... ប្រាប់ខ្ញុំមក៏ ប្រាប់ខ្ញុំមក៏គេថាដូចម្ដេចដែរ បងស្រី។



គេថាអ្វីៗ អ្វីៗទាំងអស់ គឺត្រូវបានសកលលោកដ៏ធំនេះស្រូប
យក គឺអ្វីៗទាំងអស់ត្រូវបានសកលលោកដ៏ធំនេះស្រូបទាញមក
ខ្លួនវា។



គេនិយាយថា វត្ថុធំទាញវត្ថុតូចខ្លាំងជាងវត្ថុតូចទាញវត្ថុធំ។ ប៉ុន្តែ ហេតុអ្វីបានជាវត្ថុមិនជ្រុះឡើងលើ ហេតុអ្វីបានជាវត្ថុមិនជ្រុះ ឡើងលើ បងស្រី? ចាំ ចាំបន្តិចប្អូន ប្រុសតូច។



គេនិយាយថា ផែនដី ជាទីជម្រករបស់មនុស្សនិងសត្វ គឺជាវត្ថុដ៏ធំ ហើយពួកយើង និងអ្វីៗផ្សេងទៀតដែលនៅលើផែនដីដូចជា-យន្តហោះ ត្រីបាឡែន ហើយសូម្បីតែមហាសមុទ្ររបស់យើង គឺសុទ្ធតែជាវត្ថុតូចៗ។



ដូច្នេះហើយបានជាផែនដីទាញយើងខ្លាំងជាងយើងទាញផែនដី។ ខ្លាំងដល់ថ្នាក់ពួកយើង កូនសោ ឬទងក្រវិល ឬកាក់របស់យើងមិនអាចរត់គេច អណ្តែតឡើង បាត់ទៅ ឬក៏ធ្លាក់ឡើងលើ។



កម្លាំងដ៏ខ្លាំង កម្លាំងដ៏ខ្លាំងអស្ចារ្យនេះហើយដែលផែនដីទាញយើង យើងទាំងអស់គ្នា សូម្បីតែសត្វភេនឃ្វីននៅចុងផែនដីត្រូវទាញឆ្ពោះទៅកាន់អ្វីដែលគេហៅថាទំនាញផែនដី។ តើវាជាការពិត តើវាជាការពិតទេ បងស្រី ? បងមិនដឹង បងមិនដឹងថាម៉េច ប្អូនប្រុស។ ប៉ុន្តែនៅក្នុងសៀវភៅទាំងអស់ដែលបងបានអាន គឺគេថាបែបនេះ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*Sister, Sister, Why Don't Things Fall Up?*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/

Contributing translators: Hor Pheahong and Prum Kunthearo